សំរេច

**ប្រការ ១ :** អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថា : <u>អនុវិទ្យាល័យ វត្តពីក</u> ចាប់ពីឆ្នាំ សិក្សា ១៩៩៩-២០០០ តទៅ ។

**ប្រការ ២ :** អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃអនុវិទ្យាល័យ ។

**ប្រការ ៣ :** នាយក-នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤ :** អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកអប់រំ ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ និងប្រធាននាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងអប់រំ យុវជន និងកីឡា និងប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ចាម និងនាយកអនុវិទ្យាល័យសាមី មានភារកិច្ចរៀងៗខ្លួន អនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ
ហត្ថលេខា និងត្រា
អ៊ឹម សិទ្ធី

***

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០០

## ២- សារាចរណែនាំ

### សារាចរណែនាំ លេខ ០១ អយក-សរណន
### ស្តីពីការប្រឡងបញ្ចប់គ្រប់តួមិសិក្សាផ្នែកចំណេះទូទៅ
### បំពេញវិជ្ជាសាធារណៈ និង ឯកជន

****

-យោង : ប្រកាសលេខ ........... និងលេខ .........អយក.ប្រក របស់ក្រសួងអប់រំ យុវជន និងកីឡា ចុះថ្ងៃទី ............................. ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការប្រឡងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ និង ទុតិយភូមិ

-សារាចរណែនាំអនុវត្តលេខ ០៩ អយក.សរណន-ឆទម របស់ក្រសួងអប់រំ យុវជន និងកីឡា ចុះថ្ងៃទី០៨ ខែ តុលា ឆ្នាំ ១៩៩៦

-សេចក្តីណែនាំលេខ ២៨៩១ អយក.ចទម ចុះថ្ងៃទី១៣ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការវាយតំលៃរបស់សិស្សនៅមធ្យមសិក្សា របស់ក្រសួងអប់រំ យុវជន និងកីឡា

ចាប់ពីឆ្នាំសិក្សា ១៩៩៩-២០០០ នេះតទៅ ពិន្ទុប្រឡងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ ត្រូវបោះបង់ពិន្ទុប្រចាំឆ្នាំ ប្តូរមកនឹងពិន្ទុប្រឡងថ្នាក់ជាតិ ។

ដើម្បីអោយការរៀបចំប្រឡងថ្នាក់ជាតិ និងការរៀបចំប្រលងតាមសាលារៀន មានលក្ខណៈល្អប្រសើរក្រសួងសូមធ្វើការណែនាំដូចតទៅ ៖

**I-កាលបរិច្ឆេទប្រលង :**

**I.1- ប្រឡងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ :**

-កាលបរិច្ឆេទនៃការប្រឡង : ថ្ងៃទី២៤ និង ២៥ កក្កដា ២០០០ ។

-កាលបរិច្ឆេទនៃការទទួលពាក្យសុំប្រលង : ថ្ងៃទី០១ មីនា ២០០០ ដល់ថ្ងៃទី៣១ មីនា ២០០០ ។

**I.2- ប្រឡងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ :**

-កាលបរិច្ឆេទនៃការប្រឡង : ថ្ងៃទី១៤ និង ១៥ សីហា ២០០០ ។

-កាលបរិច្ឆេទនៃការទទួលពាក្យសុំប្រឡង : ថ្ងៃទី០១ មីនា ២០០០ ដល់ថ្ងៃ៣១ មីនា ២០០០ ។

**II-លក្ខខណ្ឌសិស្ស និងសំណុំលិខិតដាក់ពាក្យសុំប្រឡង :**

II.1-សំណុំលិខិតដាក់ពាក្យសុំប្រឡងរបស់បេក្ខជន ត្រូវសរសេរដោយដៃបេក្ខជនផ្ទាល់ (គំរូជូនភ្ជាប់) បិទតែម ៣០០៛ និងមានភ្ជាប់បង្កាន់ដៃបង់សិទ្ធិប្រឡងដូចខាងក្រោម ៖

-បេក្ខជនប្រឡងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ បង់ថ្លៃសិទ្ធិប្រឡង ១០០០៛ ។

-បេក្ខជនប្រឡងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ បង់ថ្លៃសិទ្ធិប្រឡង ១៥០០៛ ។

**II.2- លក្ខខណ្ឌ :**

★សិស្សសាលារៀនចំណេះទូទៅសាធារណៈ និងឯកជនដែលមានអាយុ ១៥ឆ្នាំ នឹងបានរៀននៅមធ្យមសិក្សាបឋមភូមិគ្រប់កំរិតថ្នាក់ និងរៀនចប់កម្មវិធីថ្នាក់ទី៩ ដោយគោរពបានត្រឹមត្រូវនូវបទបញ្ជាផ្ទៃក្នុងសំរាប់គ្រឹះស្ថានមធ្យមសិក្សា ហើយត្រូវបានវាយតម្លៃផ្នែកសីលធម៌ប្រចាំឆ្នាំ ចាប់ពីមធ្យមសិក្សាឡើងទៅ និងអតីតបេក្ខជនដែលបានប្រឡងធ្លាក់សញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ (បេក្ខជនសេរី) អាចដាក់ពាក្យសុំប្រឡងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ និងសិស្សដែលបានរៀននៅមធ្យមសិក្សាទុតិយភូមិ គ្រប់កំរិតថ្នាក់ និងបានរៀនចប់កម្មវិធីថ្នាក់ទី១២ ហើយមានសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ និងគោរពបានត្រឹមត្រូវនូវបទបញ្ជាផ្ទៃក្នុងសំរាប់គ្រឹះស្ថានមធ្យមសិក្សា ហើយត្រូវបានវាយតំលៃផ្នែកសីលធម៌ប្រចាំឆ្នាំ ចាប់ពីមធ្យមឡើងទៅ និងអតីតបេក្ខជនដែលបានប្រលងធ្លាក់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ អាចដាក់ពាក្យសុំប្រឡងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ នៅតាមគ្រឹះស្ថានសិក្សារបស់ខ្លួនបាន លើកលែងតែសិស្សសាលារៀនចំណេះទូទៅសាធារណៈ និងឯកជនដែល :

-ឈប់ឥតច្បាប់លើសពី២០ដងឡើងទៅ ។

-ឬឈប់មានច្បាប់ និងឥតច្បាប់លើសពី៣០ដងឡើងទៅ ។

-ឬឈប់មានច្បាប់ លើសពី៤៥ដងឡើងទៅ ។

-ឬគ្មានពិន្ទុ ឆមាសទី១ ឬ ឆមាស ទី២

-ឬទទួលការវាយតំលៃខ្សោយ លើផ្នែកសីលធម៌រស់នៅ

★អតីតបេក្ខជនដែលបានប្រលងធ្លាក់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ អាចដាក់ពាក្យសុំប្រឡងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ នៅតាមមន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-ក្រុង ដែលគេធ្លាប់បានសុំប្រឡងពីមុន ឬ អាចដាក់ពាក្យសុំប្រលងនៅតាមមន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-ក្រុង ផ្សេងទៀត ដោយគ្រាន់តែធ្វើសេចក្ដីបញ្ជាក់ពីការប្រលងធ្លាក់ លើពាក្យសុំប្រឡងពីមន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-ក្រុង ដែលគេធ្លាប់បានប្រឡងធ្លាក់ពីមុន ។

★<u>**កំណត់សំគាល់**</u> :

-ចំនួនអវត្តមានត្រូវគិតចាប់ពីបវេសនកាល រហូតដល់ថ្ងៃទី ២០ តុលា ២០០០ ។

-លោកនាយកសាលា :

★ ត្រូវពិនិត្យសំណុំលិខិតដាក់ពាក្យសុំប្រឡងរបស់សិស្ស ដោយផ្ទៀងផ្ទាត់អោយបានត្រឹមត្រូវនូវឈ្មោះ ថ្ងៃ............ខែ .......... ឆ្នាំកំណើត ទីកន្លែងកំណើត ឈ្មោះឪពុក ម្ដាយរបស់សិស្សដែលសរសេរក្នុងពាក្យសុំប្រឡង និង សលាកប័ត្រឯកត្តជន និងអត្តសញ្ញាណប័ណ្ណ ។ ពាក្យសុំប្រឡង និងសលាកប័ត្រឯកត្តជនរបស់សិស្ស ត្រូវសរសេរអោយច្បាស់ទូអក្សរ ហើយមិនត្រូវសរសេរត្រួត រឺ កោសលុបឡើយ ។ បើមានករណីបែបនេះ ត្រូវអោយសិស្សសរសេរសាជាថ្មីឡើងវិញ ។

★ត្រូវចុះហត្ថលេខា និង បោះត្រាលើសលាកប័ត្រពិន្ទុប្រចាំឆ្នាំរបស់បេក្ខជន (បេក្ខជនម្នាក់បំពេញបួនច្បាប់) ដែលសរសេរបំពេញដោយផ្ទាល់ដៃសិស្ស ចៀសវាងការកោសលុប រឺសរសេរត្រួត ។

★ត្រូវណែនាំអោយសិស្សសរសេរសំណុំលិខិតដាក់ពាក្យសុំប្រឡងដោយខ្លួនឯង ចៀសវាងប្រមូលយកទៅអោយអនុរក្ស ឬគ្រូទទួលបន្ទុកថ្នាក់ ឬមិត្តភក្តិសរសេរជំនួស ។

បន្ទាប់ពីឈប់ទទួលពាក្យសុំប្រឡង ត្រូវរាប់ចំនួនសិស្សដាក់ពាក្យសុំប្រឡងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ និងចំនួនសិស្សដាក់ពាក្យសុំប្រឡងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ផ្ញើទៅមន្ទីរអប់រំយុវជន និងកីឡា ខេត្ត-ក្រុង ដើម្បីមន្ទីរធ្វើសំណើកំណត់មណ្ឌលប្រឡង ផ្ញើទៅក្រសួងអប់រំ យុវជន និងកីឡា ទាន់ពេលវេលា ។ ឯសំណុំលិខិតផ្សេងៗ ត្រូវផ្ញើទៅមន្ទីរអប់រំ យុវជន និងកីឡា ជាបន្តបន្ទាប់ ។

**III-ការកំណត់មណ្ឌលប្រលង :**

កន្លងមកគ្រឹះស្ថានសិក្សាមួយចំនួនតាមខេត្ត-ក្រុង ដែលយកធ្វើជាមណ្ឌលប្រឡងពុំទាន់បានរៀបចំអោយអស់លទ្ធភាព ដើម្បីធានាអោយដំណើរការប្រឡងប្រព្រឹត្តទៅបានល្អប្រសើរនៅឡើយ ។

ចំពោះលោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា ត្រូវជ្រើសរើសយកគ្រឹះស្ថានសិក្សាណាដែលមានរបងព័ទ្ធជុំវិញ មានក្រឡាពន្លឺគួរសមត្រឹមត្រូវ ដើម្បីធ្វើជាមណ្ឌលប្រឡង និងត្រូវណែនាំអោយនាយកគ្រឹះស្ថានសិក្សារបស់ខ្លួនយកធ្វើជាមណ្ឌលប្រឡង សំអាតទីធ្លា អាគារ បន្ទប់អនាម័យ អោយហើយស្រេចមុនដំណើរការប្រឡង ។ បន្ទប់ប្រឡងនីមួយៗត្រូវរៀបចំអោយមានតុ ជើងមាំទាំ ដើម្បីអោយបេក្ខជនងាយស្រួលក្នុងការសរសេរកិច្ចការ ។ ហើយតុ ជើងមាំមាំទាំ ត្រូវជួសជុល ឬ រកជើងមាំទាំមកប្តូរ ។

មណ្ឌលប្រឡងនីមួយៗត្រូវមានប្រធានមណ្ឌលដែលអាចទុកចិត្តបាននៅពេលដំណើរការប្រឡង ។ ប្រធានមណ្ឌលអាចជានាយកគ្រឹះស្ថានសិក្សា ដែលត្រូវបានយកធ្វើជាមណ្ឌលប្រឡង ត្រូវជ្រើសរើសក្នុងចំណោមបុគ្គលិកដែលគេទុកចិត្ត និងរៀបចំប្រគល់ប៉ូលិសដំរែង ហើយសកម្មក្នុងការដោះស្រាយបញ្ហាខាតសំភារៈផ្សេងៗ ។

ហាមឃាត់ជួរលក់ដូរនៅក្នុងមណ្ឌលប្រឡងក្នុងរយៈពេលដំណើរការប្រឡង ។

ត្រូវផ្ញើការកំណត់មណ្ឌលប្រឡងទៅនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ អោយបានមុនថ្ងៃ៣០ ឧសភា ២០០០ ។ (ជូនភ្ជាប់គំរូតារាងកំណត់មណ្ឌលប្រឡង) ។

**IV-សំណេរប្រធានវិញ្ញាសាប្រឡង :**

លោកគ្រូ-អ្នកគ្រូបង្រៀនថ្នាក់ទី១២ ឬ បង្រៀនថ្នាក់ទី៩ នៃមធ្យមសិក្សាត្រូវធ្វើសំណេរប្រធានវិញ្ញាសា តាមមុខវិជ្ជាប្រឡង ចំនួនមុខប្រធានវិញ្ញាសាសំរាប់មធ្យមសិក្សាទុតិយភូមិ និងមុខប្រធានវិញ្ញាសាសំរាប់មធ្យមសិក្សាបឋមភូមិ ដោយភ្ជាប់អត្រាកំណែមកជាមួយ ដើម្បីអោយក្រសួងពិចារណា និងជ្រើសរើស ។

លោកគ្រូ-អ្នកគ្រូដែលមានភារកិច្ចធ្វើសំណេរប្រធានវិញ្ញាសាត្រូវរក្សាអោយបាន ម៉ឺងម៉ាត់នូវការសំងាត់ និងគំរោងមុខវិជ្ជារបស់ខ្លួន និងទទួលខុសត្រូវចំពោះមុខក្រសួង ។

ផ្នែកខាងលើនៃសំណេរប្រធានវិញ្ញាសានីមួយៗ ត្រូវសរសេរតាមគំរូជូនភ្ជាប់ ។ សំណេរប្រធានវិញ្ញាសានីមួយៗ ត្រូវដាក់ក្នុងស្រោមសំងាត់ដោយបញ្ជាក់មុខវិជ្ជាលើស្រោមនោះ ។

នាយកវិទ្យាល័យ អនុវិទ្យាល័យ ត្រូវប្រមូលស្រោមសំណេរប្រធានវិញ្ញាសាទាំងអស់ដាក់ក្នុងស្រោមសំងាត់រួម រួចផ្ញើទៅ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ តាមរយៈមន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-ក្រុង អោយបានមុនថ្ងៃ ៣០ ឧសភា ២០០០ ។

**ចំពោះវិញ្ញាសាដែលត្រូវធ្វើសំណេរមានដូចតទៅ :**

ក-<u>សំរាប់ការប្រឡងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ</u> :

១-តែងសេចក្តី ........................ រយៈពេល ២ម៉ោង ៣០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ១៥០

២-គណិតវិទ្យា ........................ រយៈពេល ២ម៉ោង ៣០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ១៥០

៣-រូបវិទ្យា ........................ រយៈពេល ១ម៉ោង ត្រូវបានពិន្ទុ ពី ០ ដល់ ៥០

៤-គីមី ............................ រយៈពេល ១ម៉ោង ត្រូវបានពិន្ទុ ពី ០ ដល់ ៥០

៥-ជីវវិទ្យា ............................ រយៈពេល ១ម៉ោង ត្រូវបានពិន្ទុ ពី ០ ដល់ ៥០

៦-ទស្សនវិជ្ជា ............................ រយៈពេល ១ម៉ោង ត្រូវបានពិន្ទុ ពី ០ ដល់ ៥០

៧-ប្រវត្តិវិទ្យា ............................ រយៈពេល ១ម៉ោង ត្រូវបានពិន្ទុ ពី ០ ដល់ ៥០

៨-ភូមិវិទ្យា ............................ រយៈពេល ១ម៉ោង ត្រូវបានពិន្ទុ ពី ០ ដល់ ៥០

ខ-<u>សំរាប់ការប្រឡងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ</u> ៖

១-ភាសាខ្មែរ ............................ រយៈពេល ២ម៉ោង ត្រូវបានពិន្ទុ ពី ០ ដល់ ១០០

២-គណិតវិទ្យា ............................ រយៈពេល ២ម៉ោង ត្រូវបានពិន្ទុ ពី ០ ដល់ ១០០

៣-រូបវិទ្យា ............................ រយៈពេល ៤០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ៣០

៤-គីមី ............................ រយៈពេល ៤០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ២៨

៥-ជីវវិទ្យា ............................ រយៈពេល ៤០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ២៨

៦-ផែនដីវិទ្យា ............................ រយៈពេល ៤០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ២៨

៧-សីលធម៌ - ពលរដ្ឋវិជ្ជា ............... រយៈពេល ៤០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ៣០

៨-ភូមិវិទ្យា ............................ រយៈពេល ៤០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ២៨

៩-ប្រវត្តិវិទ្យា ............................ រយៈពេល ៤០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ២៨

១០-ជីវភាសា ............................ រយៈពេល ៤៥នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ៥០

**V- ការផ្តល់ពិន្ទុប្រចាំឆ្នាំ ទៅក្រសួង ៖**

នាយកវិទ្យាល័យ - អនុវិទ្យាល័យ និងសាលារៀនក្រោមឱវាទផ្ទាល់របស់ក្រសួង ត្រូវផ្ញើទៅក្រសួង (អោយកេដ្ឋានមធ្យមសិក្សាចំណេះទូទៅ) តាមរយៈមន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-ក្រុង នូវ ៖

ក) បញ្ជីមធ្យមភាគពិន្ទុឆមាសទី១ របស់សិស្សថ្នាក់ទី៩ និងទី ១២ អោយបានមុនថ្ងៃ២៧ មីនា ២០០០ (តាមគំរូភ្ជាប់) ។

ខ) បញ្ជីពិន្ទុប្រចាំឆ្នាំរបស់សិស្សថ្នាក់ទី៩ និងទី ១២ អោយបានមុនថ្ងៃ១០ កក្កដា ២០០០ (តាមគំរូភ្ជាប់) ។

គ) មន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង ទទួលខុសត្រូវលើការបោះពុម្ពគោលវិញ្ញាសាប្រឡងឆមាសនៃថ្នាក់ទី១២ ។ រីឯប្រធានវិញ្ញាសាប្រឡងឆមាសនៃថ្នាក់ទី៩ គឺគណៈគ្រូបង្រៀនផ្ទាល់ជាអ្នកទទួលខុសត្រូវ ។

លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា គ្រប់ខេត្ត-ក្រុង ត្រូវផ្សព្វផ្សាយការណែនាំនេះដល់គ្រប់គ្រឹះស្ថានមធ្យមសិក្សាក្រោមឱវាទ ដើម្បីអោយការអនុវត្តន៍មានប្រសិទ្ធភាព ។

រដ្ឋលេខាធិការ
ហត្ថលេខា និងត្រា
អ៊ឹម សិទ្ធី

★★★